ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

# សារលិខិតជូនពរ
# លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា
# លោកជំទាវ លោក-លោកស្រី នាងកញ្ញា ជាប្រធានក្រុមប្រឹក្សាភិបាល
# អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស និងសាធារណជនទាំងអស់
# ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០

នៅក្នុងឱកាសដ៏មហាមង្គលាភិរម្យថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយបំផុត នៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៦ ខែមេសា ខាងមុខនេះ ខ្ញុំសូមសម្តែងនូវអំណរសាទរឥតឧបមា និងសូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការចំពោះ **លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក-លោកស្រី នាងកញ្ញា** ជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស និងសាធារណជនទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូណ៌ អាយុយឺនយូរ កម្លាំងមាំមួន និងសូមឱ្យការប្រកបអាជីវកម្មរកទទួលទានកាន់តែរីកដុះដាល និងរីកចម្រើនជាលំដាប់។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះ ខ្ញុំសូមលើកហត្ថប្រណម្យសូមដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ព្រះនាម **រាក្សសាទេវី** ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមតាមបីបាច់ថែរក្សាការពារប្រោះព្រំប្រទានសព្ទសាធុការពរជ័យ ជូនចំពោះ **លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក-លោកស្រី នាងកញ្ញា** ជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស និងសាធារណជនទាំងអស់ ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក-លោកស្រី នាងកញ្ញា ជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ម្ចាស់សហគ្រាស និងសាធារណជនទាំងអស់ ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ

ថ្ងៃពុធ ១៤កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១ ខែមេសា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh